# សេចក្តីប្រកាសព័ត៌មានរបស់កម្មវិធីស្បៀងអាហារពិភពលោក

២៨ មិថុនា ២០២១

## កម្មវិធីស្បៀងអាហារពិភពលោកសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីផ្តល់ស្បៀងជូនដល់ប្រជាពលរដ្ឋចំនួន២០០.០០០នាក់

រាជធានីភ្នំពេញ – ថ្ងៃនេះ កម្មវិធីស្បៀងអាហារពិភពលោក សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីចែកស្បៀងជូនដល់ក្រុមគ្រួសារងាយរងគ្រោះចំនួន៣៩.៦៥០គ្រួសារ ដែលក្នុងនោះមានប្រជាពលរដ្ឋសរុបដែលទទួលបានជំនួយនេះប្រហែល២០០.០០០នាក់ នៅក្នុងខេត្តចំនួនប្រាំ។

ជំនួយនេះសម្រាប់ផ្តល់ជូនដល់ក្រុមគ្រួសារដែលអាជ្ញាធរកំណត់ថាជាគ្រួសារងាយរងគ្រោះ មានប័ណ្ណអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (IDPoor) និងមានកូនចុះឈ្មោះចូលរៀននៅតាមសាលាដែលមានការគាំទ្រពីកម្មវិធីផ្តល់ស្បៀងអាហារតាមសាលារៀន របស់កម្មវិធីស្បៀងអាហារពិភពលោក និងក្រសួងអប់រំ យុវជន និងកីឡា។

ជាធម្មតា កម្មវិធីផ្តល់ស្បៀងអាហារតាមសាលារៀន របស់កម្មវិធីស្បៀងអាហារពិភពលោក និងក្រសួងអប់រំយុវជននិងកីឡា ផ្តល់នូវអាហារសុខភាពនិងមានជីវជាតិដល់កុមារចំនួន២២៣.០០០នាក់ នៅតាមសាលាគោលដៅចំនួន៩០៨ នៅក្នុងខេត្តចំនួនប្រាំគឺ សៀមរាប ឧត្តរមានជ័យ កំពង់ធំ កំពង់ឆ្នាំង និងពោធិ៍សាត់។ អាហារូបត្ថម្ភល្អមានសារៈសំខាន់ណាស់សម្រាប់ការអភិវឌ្ឍផ្លូវចិត្តនិងរាងកាយរបស់កុមារ។ ការសិក្សាបានបង្ហាញថា ការផ្តល់អាហារតាមសាលារៀនជួយឱ្យសិស្សផ្តោតអារម្មណ៍និងរៀនសូត្រឆាប់ចេះចាំ រួមចំណែកឱ្យមានលទ្ធផលនៃការអប់រំប្រសើរឡើង ព្រមទាំងជួយសម្រាលបន្ទុកសេដ្ឋកិច្ចរបស់ក្រុមគ្រួសារសិស្សផងដែរ។

ចាប់តាំងពីមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងការផ្អាកដំណើរការសាលារៀន សិស្សមិនបានទទួលទានអាហារពេលព្រឹកដែលមានជីវជាតិទៀតទេ។ បញ្ហានេះបានជះឥទ្ធិពលជាពិសេសដល់កុមារមកពីគ្រួសារក្រីក្របំផុតដែលភាគច្រើនរងការលំបាកដោយសារការបាត់បង់ចំណូលនិងការងារ។

លោកស្រី ក្លែរ ខូណាន់ តំណាងកម្មវិធីស្បៀងអាហារពិភពលោកប្រចាំនៅកម្ពុជា មានប្រសាសន៍ថា "ក្នុងអំឡុងពេលមានតម្រូវការខ្ពស់ ជំនួយស្បៀងរបស់កម្មវិធីស្បៀងអាហារពិភពលោក និងក្រសួងអប់រំ យុវជន និងកីឡា គឺជាការរួមចំណែកបំពេញបន្ថែមដល់ជំនួយគាំពារសង្គមរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានពង្រីកវិសាលភាពរបស់ខ្លួននៅក្នុងប៉ុន្មានខែថ្មីៗនេះ។ ជំនួយនេះនឹងរួមចំណែកក្នុងការបំពេញតម្រូវការរបស់ក្រុមគ្រួសារងាយរងគ្រោះជាពិសេស និងធានា

ថាកុមារនឹងមានអាហារទទួលទានក្នុងពេលមានវិបត្តិ។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះដៃគូទាំងអស់ដែលបានផ្តល់ការគាំទ្រ ជាពិសេស ក្រសួងអប់រំ យុវជន និងកីឡា និងក្រុមប្រឹក្សាជាតិគាំពារសង្គម។”

នេះគឺជាការចែកស្បៀងជុំទី៤ ក្នុងគោលបំណងកាត់បន្ថយផលប៉ះពាល់របស់ជំងឺកូវីដ-១៩ ទៅលើសេដ្ឋកិច្ចគ្រួសារងាយរងគ្រោះ។ ការចែកស្បៀងត្រូវបានធ្វើឡើងតាមរយៈបណ្តាញសាលារៀន ដោយមានការគាំទ្រពីមន្ទីរអប់រំ យុវជន និងកីឡា រដ្ឋបាលសាលារៀន អាជ្ញាធរភូមិឃុំ និងដៃគូអង្គការមិនមែនរដ្ឋាភិបាល។ របបស្បៀងមាន អង្ករ២៥ គីឡូក្រាម ត្រីខកំប៉ុង និងប្រេងឆា។ ក្រៅពីនេះ កម្មវិធីស្បៀងអាហារពិភពលោកកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងអប់រំ យុវជន និងកីឡា និងដៃគូដទៃទៀត ដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធសាលារៀននិងអគារសិក្សា ដែលជាវិធានការត្រៀមសម្រាប់ការចូលរៀនវិញប្រកបដោយសុវត្ថិភាព។

កម្មវិធីផ្តល់ស្បៀងអាហារតាមសាលារៀននៅកម្ពុជា និងជំនួយស្បៀងពិសេសនេះ អាចប្រព្រឹត្តទៅបានដោយមានជំនួយឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលជប៉ុន ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (**KOICA**) និងក្រសួងកសិកម្មនៃសហរដ្ឋអាមេរិក (**USDA**)។

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង (អ៊ីម៉ែល chou.chea@wfp.org)៖**
លោកស្រី ជា ជូ កម្មវិធីស្បៀងអាហារពិភពលោកកម្ពុជា ទូរស័ព្ទលេខ៖ **+855 78 565 283**